សាលាព្រះគម្ពីរភ្នំពេញ

ខែមីនា ២០១៣ លេខ១

# វាលស្រែស្រូវទុំ

## ព័ន្ធកិច្ចកម្មសិក្សា ១-៨ មីនា ២០១៣

និស្សិតសាលាព្រះគម្ពីរភ្នំពេញបានចុះធ្វើព័ន្ធកិច្ចកម្មសិក្សាតាមក្រុមតូចនៅបណ្ដាខេត្ត ដែលមានទាំងអស់៨ក្រុម ក្នុងគោលបំណងឲ្យនិស្សិតទទួលបទពិសោធន៍ ផ្សារភ្ជាប់ការសិក្សាទៅនឹងការអនុវត្តន៍។ ក្រុមតូចនីមួយៗមានគ្រូ ឬសាស្ត្រាចារ្យម្នាក់ដឹកនាំ ដោយបានសហការជាមួយពួកជំនុំនៅតាមទីកន្លែងនីមួយៗ។ ក្នុងកម្មសិក្សានេះ និស្សិតអាចបង្រៀនកុមារ យុវជន និង ចាស់ៗតាមសំណូមពរនៃពួកជំនុំ។ កម្មសិក្សានេះពិតជាផ្ដល់អត្ថប្រយោជន៍ជាច្រើនដល់គ្រូនិងនិស្សិតទាំងអស់របស់យើង។



## និស្សិតយើងទទួលបានបទពិសោធន៍ជាច្រើន

**សុម៉ាលី (ឆ្នាំទី២):** “ដំណើរព័ន្ធកិច្ចទៅខេត្តកំពង់ស្ពឺបានធ្វើឲ្យនាងខ្ញុំកាន់តែចង់បម្រើព្រះថែមទៀត។ ខ្ញុំបានរៀនមុខវិជ្ជាផ្សាយដំណឹងល្អពីមុន ហើយគ្រូខ្ញុំបានឲ្យយើងអនុវត្តផ្សាយដំណឹងល្អខាងក្រៅ។ ខ្ញុំធ្វើតាមដោយសារតែចង់ជាប់មុខវិជ្ជានោះតែប៉ុណ្ណោះ ប៉ុន្តែ ក្នុងដំណើរព័ន្ធកិច្ចលើកនេះ ពិតជាបានផ្លាស់ប្ដូរគំនិតរបស់ខ្ញុំ។ តាមពិត នេះជាលើកទីមួយដែលខ្ញុំផ្សាយដំណឹងល្អចេញពីចិត្តរបស់ខ្ញុំ ”



សុម៉ាលីផ្សាយដំណឹងល្អក្មេងៗទាំងអស់ទទួលជឿព្រះយេស៊ូវ

**ស្រីល័ក្ខ(ឆ្នាំទី១):** “ក្រុមតូចរបស់នាងខ្ញុំបានចុះទៅខេត្តពោធិសាត់។ ក្នុងពួកជំនុំដែលយើងធ្វើព័ន្ធកិច្ច ពួកគេច្រៀងថ្វាយបង្គំព្រះអស់ពីចិត្ត។ ខ្ញុំឃើញពីសេចក្ដីត្រូវការនៅក្នុងភូមិ។ នៅក្នុងភូមិ១នោះ មានក្មេងៗប្រហែល៧០នាក់។ ឯភូមិមួយទៀតមានក្មេងៗ ប្រហែល៣០នាក់ តែមានគ្រូតែម្នាក់គត់បង្រៀនពួកគេ។ ខ្ញុំពិតជាអាណិតពួកគេ ពួកគេឆ្លាតណាស់ តែគ្មានគ្រូគ្រប់គ្រាន់ដើម្បីបង្រៀនពួកគេទេ។ គ្រូគង្វាលតែម្នាក់ តែគាត់បម្រើពួកជំនុំ៣កន្លែង។ ពួកគេពិតជា ស្រេកឃ្លានចង់ស្ដាប់ព្រះបន្ទូលធ្វើឲ្យចិត្តខ្ញុំឆេះឆួលជាថ្មីសម្រាប់ព្រះជាម្ចាស់ ហើយខ្ញុំមិនគួរមានសេចក្ដីខ្មាស់នឹងផ្សាយដំណឹងល្អឡើយ” ។

**ម៉ូហ្សេ(ឆ្នាំទី៣):** “ជីវិតនៅតាមជនបទពិតជាពិបាកណាស់។ ពេលខ្លះយើងមិនខ្វល់នឹងព្រះគុណព្រះទេពេលយើងរស់នៅបានសុខស្រួលនៅទីក្រុង។ គ្រូគង្វាលនៅជនបទខិតខំធ្វើការណាស់។ ផ្លូវលំតាមជនបទពិតជាពិបាកធ្វើដំណើរ។ គាត់ជិះកង់ទៅផ្សាយដំណឹងល្អពីភូមិ១ទៅភូមិ១ទៀត។ ពេលខ្លះគាត់មិនអាចផ្គត់ផ្គង់គ្រួសារគាត់ឲ្យបានគ្រប់គ្រាន់ទេ។ ខ្ញុំរៀនហើយដឹងថាជាគ្រូគង្វាលនិងជាអ្នកដឹកនាំពួកជំនុំ ខ្ញុំត្រូវតែសុខចិត្តរងទុក្ខលំបាកដើម្បីដំណឹងល្អ។





# ស្លាបនាសហាគមន៍&សេចក្ដីប្រកបក្នុងសាលាព្រះគម្ពីរភ្នំពេញ

## ណូអែល ជាពេលសម្រាប់...

និស្សិតនិងបុគ្គលិកនៅPPBSបានប្រារព្ធពិធីកំណើតព្រះយេស៊ូវជាមួយគ្នា គឺជាព្រឹត្តិការណ៍យ៉ាងវិសេស។ មានការចូលរួមពិធីថ្វាយបង្គំយ៉ាងច្រើនពីសហាគមន៍ នាំយកអំណោយនិងទេពកោសល្យថ្វាយព្រះ ដើម្បីតម្កើងទ្រង់និងប្រារព្ធពិធី "អ៊ីម៉ាញ៉ូអែល - ព្រះគង់ជាមួយ " ។ និស្សិតបានសម្ដែងល្ខោនពណ៌នាពីសេចក្ដីសន្យារបស់ព្រះដែលបានបំពេញសម្រេចក្នុងព្រះជន្មកំណើតរបស់ព្រះយេស៊ូវ។ លោកមហាវិទ្យាធិការ ធីម៉ូថេ អ៊ិត បានរំលឹកក្នុងសេចក្ដីអធិប្បាយរបស់គាត់ពីការបន្ទាបខ្លួនរបស់ព្រះយេស៊ូវនិងបានយាងមកដើម្បីបម្រើ សម្រាប់ថ្វាយសិរីល្អដល់ព្រះ។





.យើងរីករាយនឹងការទទួលទានអាហារជាមួយគ្នា ហើយនៅពេលយប់មានការប្រឡងសម្ដែងនៅតាមសយនដ្ឋាន ដែលជ័យជំនះបានទៅសយនដ្ឋានខាងបុរស។

## ទិវាកីឡា ១០ មករា ២០១៣





និស្សិតជិត៥៥នាក់រួមទាំងបុគ្គលិក និងសាស្ត្រាចារ្យ ២៧នាក់នៅសាលាព្រះគម្ពីរភ្នំពេញ បានចំណាយពេលប្រកបគ្នាដ៏មានតម្លៃ ក្នុងគោលដៅស្អាងភាពរួបរួម ការស្គាល់គ្នា ទំនាក់ទំនងប្រកបដោយអំណរ និង ទំនាក់ទំនងល្អក្នុងការងារ។ ពីព្រោះយើងមានចំណែកក្នុងនគរដ៏អស់កល្បរបស់ព្រះ មិត្តភាព ដែលបានបង្កើតនៅPPBSនឹងឲ្យយើងរួបរួមក្នុងពេលយើងកំពុងបម្រើព្រះជាមួយគ្នាក្នុងពិភពលោកនេះ។

ក្នុងទិវាកីឡាកាលពីខែមករាគឺជារបៀប១ដេលយើងប្រារព្ធធ្វើដើម្បីរឹតចំណងមិត្តភាព។ ខំប្រឹងយ៉ាងខ្លាំង ដើម្បីជួយក្រុមឲ្យទទួលជ័យជំនះនោះបានចងរឹតយើងឲ្យមានសាមគ្គីភាពនិងសង់អកប្បកិរិយាយើង ! ទោះបីយើងមិនមានជំនាញខាងកីឡា តែការខំអស់ពីលទ្ធភាពជាបទពិសោធន៍យ៉ាងល្អ។ យើងរីករាយជាមួយគ្នា! ប្រហែលឆ្នាំក្រោយ យើងនឹងអញ្ជើញសាលាព្រះគម្ពីរដទៃទៀតចូលរួមទិវាកីឡាជាមួយយើងដែរ !



# “តើអ្នកចង់មកជួយឬទេ ?”



ការពិភាក្សានៅក្នុងក្រុមតូច

យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់ឱកាសផ្សាយដំណឹងល្អជាមួយបុគ្គលិកអង្គការទស្សនៈពិភពលោកក្នុងខេត្តព្រះវិហារ ទឹកដីភាគខាងលិចនៃប្រទេសកម្ពុជា។ អ្នកដឹកនាំនៃអង្គការនេះបានស្នើសុំឲ្យសាស្ត្រាចារ្យយើងមកបង្រៀនបុគ្គលិកខ្លួនពីសេចក្តីពិតជាមូលដ្ឋាននៃដំណឹងល្អរបស់ព្រះជាម្ចាស់។ កាលពីខែមករាកន្លងទៅនេះ លោកគ្រូ ណារី និង លោកគ្រូរុទ្ធីបានធ្វើដំណើរទៅខេត្តព្រះវិហារ (ចម្ងាយប្រហែល១២ម៉ោង) និងបានចំណាយពេល២ថ្ងៃ ។ បុគ្គលិកអង្គការទស្សនពិភពលោកចំនួន៦២នាក់បានឮសេចក្តីពិតពីវត្តមានរបស់ព្រះ





លោកគ្រូ ណារី

អំពើបាបនិងសេចក្តីសង្គ្រោះ។ អ្នកចូលរួមមានឱកាសពិភាក្សាក្នុងក្រុមតូចៗ និងស្តាប់ការបង្រៀនដោយមានការយកចិត្តទុកដាក់យ៉ាងខ្លាំង។ នៅថ្ងៃបន្ទាប់ លោកគ្រូណារីនិងលោកគ្រូរុទ្ធីបានបង្រៀនអ្នកដឹកនាំពួកជំនុំ៥១នាក់ដែលមកពីតំបន់ផ្សេងៗនៅក្នុងខេត្តព្រះវិហារនេះ។ នេះជាលើកទី២ហើយដែលលោកគ្រូអាចជួបជុំជាមួយនិងបង្រៀនអ្នកដឹកនាំពួកជំនុំនានាក្នុងខេត្តព្រះវិហារ។

ពួកគាត់មានឱកាសដ៏អស្ចារ្យដើម្បីបន្តទំនាក់ទំនងរបស់ពួកគេ។ ការពិភាក្សានានានិងពេលវេលាសម្រាប់សំណួរ-ចម្លើយពិតជាសកម្មនិងមានផលផ្លែ។ សូមលើកតម្កើងព្រះចំពោះសេចក្តីស្រឡាញ់ និង ព្រះគុណទ្រង់ផ្តល់ !



ការពន្លាតកម្មវិធីសិក្សានៅថ្ងៃបុណ្យអុំទូក ២៧-២៩ វិច្ឆិកា២០១២ មាន៣ខេត្តគឺ កំពត កំពង់ធំ និង បាត់ដំបង ដែលមានសមាជិកពួកជំនុំសរុប៦៣បានទទួលការបណ្តុះបណ្តាល។ ខាងក្រោមនេះជាមតិមួយចំនួនរបស់អ្នកចូលរួមវគ្គនេះ៖

“ខ្ញុំដឹងពីសេចក្តីស្រឡាញ់របស់ទ្រង់ច្រើន”





“ខ្ញុំរៀនបានច្រើនពីរបៀបរស់នៅជាគ្រីស្ទាន” “វគ្គនេះជួយឲ្យខ្ញុំស្គាល់ពីសេចក្តីសប្បុរសនិងសុចរិតរបស់ព្រះច្រើនថែមទៀត” “ឲ្យជំនឿរបស់ខ្ញុំស្រស់ស្រាយឡើងវិញ និង លើកទឹកចិត្តខ្ញុំឲ្យកាន់តែទុកចិត្តលើព្រះ”



យើងអរព្រះគុណយ៉ាងខ្លាំងដែលអាចបង្រៀនអំពីសេចក្តីស្រឡាញ់របស់ព្រះនៅកន្លែងផ្សេងៗក្នុងប្រទេសកម្ពុជា។

# ថ្ងៃខួបសាលា ១៨ មីនា ២០១៣



ជាដំបូង ខ្ញុំសូមសរសើរតម្កើងព្រះជាម្ចាស់ដែលប្រទានឱកាសឲ្យខ្ញុំបានចូលរួមថ្ងៃខួបសាលាជាមួយលោកអ្នក។ គណៈកម្មការនាយកសូមអបអរសាទរដល់បងប្អូនទាំងអស់នៅសាលាព្រះគម្ពីរភ្នំពេញក្នុងឱកាសប្រារព្ធពិធីខួបសាលាលើកទី២១។ ការសម្រេចជោគជ័យរបស់សាលាគឺជាព្រះពរដ៏ធំក្រៃលែង។

ចាប់តាំងពីពេលដែលសាលាយើងបានបង្កើតដោយលោក Daniel Lamនិងមានជំនួយពីបងប្អូនជាច្រើនទៀត យើងបានធ្វើចលនាដោយមានចក្ខុវិស័យរួមគ្នា ដោយមានជំនឿថា នេះជាឱកាសដើម្បីឲ្យប្រជាជនកម្ពុជាបានស្គាល់ព្រះ ដោយយើងរៀបចំបណ្ដុះបណ្ដាលមនុស្សដើម្បីផ្សាយដំណឹងល្អ។ ព្រះបានផ្ដល់ឲ្យយើងនូវមហាវិទ្យាធិការ មហាវិទ្យាធិការរង នាយកកម្មវិធីសិក្សា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកទាំងអស់ដែលមានការលះបង់និងប្ដេជ្ញាចិត្តខ្ពស់បម្រើការងារ ដើម្បីសុខុមាលភាពនិងការរីកចម្រើនរបស់សាលា។ មានខ្លះបានបម្រើការងារតាំងពីថ្ងៃដែលសាលាបានបង្កើតមក។ ខ្ញុំសូមអរគុណចំពោះសេចក្ដីស្រឡាញ់និងការប្ដេជ្ញាចិត្តរបស់បងប្អូនក្នុងការបម្រើការងារក្នុងសាលា។ បងប្អូនខ្លះបានលះបង់យ៉ាងខ្លាំង ដោយបានចាកចេញពីមនុស្សជាទីស្រឡាញ់នៅប្រទេសឬស្រុកកំណើតរបស់ខ្លួនដើម្បីមកបម្រើការងារក្នុងសាលា បង្រៀនព្រះបន្ទូលដល់និស្សិតយើងយ៉ាងស្មោះត្រង់។ លោកអ្នកបានជួយដល់ការប្រកាសដំណឹងល្អដល់អ្នកដែលមិនទាន់បានទទួលសេចក្ដីសង្គ្រោះនៅក្នុងប្រទេសនេះ។ តាំងពីអតីតកាលរហូតដល់បច្ចុប្បន្ន លោកអ្នកបានស្ដាប់តាមមហាបេសកកម្មរបស់ព្រះ យេស៊ូវ ដោយបានរួមចំណែកយ៉ាងធំធ្វើឲ្យសាលាបានទទួលជោគជ័យដូចឃើញសព្វថ្ងៃនេះ។ សូមអរគុណខ្លាំង ណាស់ចំពោះទឹកចិត្តលះបង់និងការបម្រើរបស់លោកអ្នក។ ខ្ញុំសូមថ្លែងអំណរគុណដល់ការប្ដេជ្ញាចិត្ត ការដឹកនាំរបស់គណៈកម្មការនាយក ដែលតែងតែយកចិត្តទុកដាក់យ៉ាងខ្លាំងដល់សាលានេះ។ សមាជិកគណៈកម្មការនាយកភាគច្រើននៅបរទេស ជាការល្អបំផុត ដែលពួកគាត់បានមកទស្សនកិច្ចនិងលើកទឹកចិត្តយើងជារឿយៗ ដោយបានអះអាងជាថ្មីពីចក្ខុវិស័យដែលសាលាបានបង្កើត។

ជាច្រើនឆ្នាំមកនេះ សាលាព្រះគម្ពីរភ្នំពេញមិនខ្វះអ្វីសោះ។ ព្រះបន្តបង្រួបង្រួមរាស្ត្រទ្រង់នៅក្នុងពិភពលោក នេះដើម្បីពង្រីកនគរទ្រង់ក្នុងប្រទេសកម្ពុជា ដោយសហការជាមួយយើង ។ ព្រះបានបណ្ដាលចិត្តមនុស្សជាច្រើន មិនត្រឹមតែផ្នែកថវិកាប៉ុណ្ណោះ ថែមទាំងសេចក្ដីអធិស្ឋានប្រចាំថ្ងៃសម្រាប់សាលាទៀតផង។

ថ្ងៃនេះយើងជួបជុំគ្នាដើម្បីថ្វាយការអរព្រះគុណដែលព្រះបានប្រទានពរ ថែរក្សា ការពារសាលាយើងអស់២១ឆ្នាំ។ យើងបានឆ្លងកាត់ឧបសគ្គយ៉ាងច្រើន យើងបន្តទុកចិត្តថាទ្រង់នឹងបន្តផ្គត់ផ្គង់បំពេញសេចក្ដីត្រូវការរបស់សាលានៅឆ្នាំខាងមុខទៀត ព្រោះទ្រង់បានសង់សាលានេះនិងបានធ្វើឲ្យរីកចម្រើនមកដល់បច្ចុប្បន្ន។ ខ្ញុំសូមលើកទឹកចិត្តអ្នកទាំងអស់ឲ្យបន្តទុកចិត្តលើសេចក្ដីស្មោះត្រង់របស់ទ្រង់ ដោយកាន់ជាប់ជំនឿនឹងស្រឡាញ់ដល់ព្រះយេស៊ូវ។ សូមឲ្យព្រះបន្ទូលក្លាយជាប្រភពនៃកម្លាំងដើម្បីបន្តកិច្ចការប្រចាំថ្ងៃនៃជីវិតយើង។ "ពីព្រោះព្រះយេហូវ៉ាទ្រង់ល្អ សេចក្ដីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ចហើយសេចក្ដីស្មោះត្រង់របស់ទ្រង់ក៏នៅអស់ទាំងដំណមនុស្សតទៅ-ទំនុកដំកើង១០០:៥ សូមព្រះជាម្ចាស់ប្រទានពរដល់លោកអ្នកនិងប្រទានពរសាលាយើង។

---

**យើងខ្ញុំសូមថ្លែងអំណរគុណចំពោះដង្វាយរបស់លោកអ្នក !**

នាម:________________________ អសយដ្ឋាន ឬ អ៊ីមែល:__________________________

លេខទូរស័ព្ទ:____________________ មកពីពួកជំនុំឬអង្គការ: _________________________

**របៀបដែលលោកអ្នកអាចថ្វាយដង្វាយ:**

$___________________ ឬ ថ្វាយដង្វាយរបស់លោកអ្នកដោយបញ្ចូលទៅក្នុងសារជីវកម្មធនាគារសឹង្ហបុរី (SBC) គណនីលេខ#1120210013824 ឬប្រគល់ជូនផ្ទាល់ដល់ផ្នែកហិរញ្ញវត្ថុរបស់សាលាព្រះគម្ពីរភ្នំពេញ។

**សូមបញ្ជាក់ឲ្យបានច្បាស់ដង្វាយរបស់លោកអ្នកសម្រាប់:**

- ការប្រើប្រាស់ទូទៅ ☐
- ឧបត្ថម្ភដល់និស្សិត ☐
- អភិវឌ្ឍអាគារសិក្សា ☐
- ឧបត្ថម្ភដល់បណ្ណាល័យ ☐
- ឧបត្ថម្ភដល់ការបំពាក់គ្រឿងបរិក្ខាសាលា ☐